ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៦១៤

ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៩៩

សាលដីកា

លេខ : ២២៤

ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១_ ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២_លោក ម៉ែន ស៊ីន ជាចៅក្រម

៣_លោក វៀល មួន ជាចៅក្រម

៤_លោក ជីវ កេង ជាចៅក្រម

៥_លោក ស៊ិន ឌឹម ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខពីសាលដីការដ្ឋប្បវេណី ៤១៥ ចុះថ្ងៃទី០៥.៧.៩៩ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ២០០ ចុះថ្ងៃទី ១៩.៤.៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្ដឹងសាទុក្ខឈ្មោះ គង់ សម្បត្តិ ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ របរកស៊ី ពាណិជ្ជករ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១៩៩ ផ្លូវ ១៩៩ ភូមិស្លែងលើង ក្រុម ១ សង្កាត់ទឹកថ្លា ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ អួន ពិន "ស" ម្ដាយឈ្មោះ នាង សយ "ស" ។ ដែលមានលោក ឌី បូរីម៉ា ជាមេធាវី ។

និង ចុងបណ្ដឹងសាទុក្ខឈ្មោះ គីម ហេង ភេទស្រី អាយុ ៣៨ឆ្នាំ ជាតិខ្មែរ របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ២២៣អាបេ ផ្លូវលេខ ១៨២ "ទេពផន" សង្កាត់ទឹកល្អក់ទី២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

តតីយជន ឈ្មោះ ខាំ ភៀន ភេទស្រី អាយុ ៤៣ឆ្នាំ ជាតិខ្មែរ របរកស៊ី នៅផ្ទះ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១០ ផ្លូវលេខ ២៥៧ សង្កាត់បឹងកេងកងទី១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ប្ដីឈ្មោះ ប៊ូ ថង ។

កម្មវត្ថុបណ្ដឹង : សុំបដិសេធបណ្ណ័សំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខភ៣០០៧៦២ ចុះថ្ងៃទី ២៩.៥.៩៨ និង ជំងឺចិត្ត ៥.០០០ ដុល្លា ។

តាមបណ្ដឹងសាទុក្ខលេខ ២៤៤ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់ ឈ្មោះ គង់ សម្បត្តិ ប្ដឹងមិនសុខចិត្តពីសាលដីកាលេខ ៤១៥ ចុះថ្ងៃទី ០៥.៧.៩៩ របស់

សាលាឧទ្ធរណ៍ លើចំនុច នៃសេចក្តីសំរេចទាំងមូល ។

បានឃើញឈ្មោះរឿងរដ្ឋប្បវេណីលេខ ២១៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៥.១០.៩៨ របស់ឈ្មោះ គង់ សម្បត្តិ បញ្ជាក់ថា ខ្លួនបានយកបណ្ណ័សំគាល់កម្មសិទ្ធិ អចលនវត្ថុលេខ ភព ០០៧៦២ អោយនាង គីម ហេង ជួយយកទៅដាក់បញ្ចាំយកប្រាក់ចំនួន ៥៨.៥០០ ដុល្លាអាមេរិក ដើម្បីយកទៅសងបំណុលក្រុមហ៊ុន មុត ដឹម ។ ក្រោយមកខ្លួនទទួលដំណឹងថា នាង គីម ហេង ដាក់យកប្រាក់ចំនួន ៨០.០០០ ដុល្លាអាមេរិក ហើយបានប្រគល់ប្រាក់ ១០.០០០ដុល្លា អោយក្រុមហ៊ុន មុត ដឹម ដោយពុំប្រាប់ខ្លួនសោះ ប្រាក់នៅសល់ ៧០.០០០ដុល្លា នាងគីម ហេង ពុំបានប្រគល់ អោយខ្លួនទេ ក្រោយមកខ្លួនបានទទួលដំណឹងថា នាង គីម ហេង ជាប់គុក ពីបទជំពាក់ប្រាក់គេ ទើបខ្លួនប្តឹងបដិសេធ ប័ណ្ណកម្មសិទ្ធិកាន់កាប់អចលវត្ថុនោះចោល ។

បានឃើញសាលក្រមលេខ ៧៨ "ខ" ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ ។

១_ ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ គង់ សម្បត្តិ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៨ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_បដិសេធលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុ ចុះថ្ងៃទី ០៨.៦.៩៨ រវាងឈ្មោះ គង់ សម្បត្តិ និង គឹម ហេង ចោលជាអសារបង់ ។

៣_ត្រូវទុកជាមោឃះ នូវបណ្ណ័សំគាល់ម្ចាស់អចលនវត្ថុលេខ ភព០០៧៦២ ចុះថ្ងៃទី ២៩.៥.៩៨ ចាប់ពីថ្ងៃសាលក្រមមានប្រសិទ្ធិភាពអនុវត្ត ។

៤_អនុញ្ញាតិអោយឈ្មោះ គង់ សម្បត្តិ សុំបណ្ណ័សំគាល់អចលនវត្ថុថ្មី ពីក្រសួងមានសមត្ថកិច្ច លើអចលនទ្រព្យរបស់ខ្លួន ខាងលើ ចាប់ពីសាលក្រមមានប្រសិទ្ធិភាពអនុវត្ត ដើម្បីប្រើប្រាស់តាមផ្លូវច្បាប់តទៅ ។

៥_អោយឈ្មោះ គង់ សម្បត្តិ សងប្រាក់ដើមចំនួន ១០.០០០ដុល្លាអាមេរិក "មួយម៉ឺនដុល្លា" និង ការប្រាក់ ២០ភាគរយ ក្នុងមួយឆ្នាំ គិតពីថ្ងៃទី ០៨.៦.៩៨ រហូតដល់ថ្ងៃនេះទៅអោយឈ្មោះ គីម ហេង តាមបញ្ញត្តិមាត្រាទី ១៥៨_១៦០ នៃច្បាប់ភូមិបាល ចាប់ពីថ្ងៃសាលក្រមមានប្រសិទ្ធិភាពអនុវត្ត ។

៦_បង្គាប់អោយ គឹម ហេង បង់ប្រាក់ប្រដាប់ក្តី និង ពន្ធហ្វឹង ១.៨០០៛ ៖.ង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់សាក្សី ២.០០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៣.០០០៛ សរុបចំនួន ៧.០០០៛ ប្រាក់នេះបានកាត់យកពី ដើមចោទ ដែលបានបង់រួចហើយ .

កាលបើផុតបណ្ដឹងឧទ្ធរណ៍ អោយនាង គឹម ហេង សងប្រាក់ ៧.០០០៛ អោយ គង់សម្បត្តិ វិញ ហើយអោយបង់ពន្ធសមាមាត្រមួយភាគរយ លើទឹកប្រាក់ដែល គង់ សម្បត្តិ ត្រូវសងអោយនាង គឹម ហេង ប្រាក់នេះបានបង់ចូលថវិការដ្ឋ ចំនួន ៨០ ភាគរយ និងបានជារង្វាន់ក្រឡាបញ្ជី ទូទាំងប្រទេស ២០ភាគរយ ។

៧_សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខ គូក្ដី បើកផ្លូវឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះ ទី ពៅ ជាមេធាវីការពារអោយឈ្មោះ គឹម ហេង ចុះថ្ងៃទី ២៣.០២.៩៩ ប្ដឹងមិនសុខចិត្ត លើសេចក្ដីសំរេច នៃ សាលក្រមទាំងមូល ។

បានឃើញសាលដីកា របស់សាលាឧទ្ធរណ៍លេខ ៤១៥ ចុះថ្ងៃទី ០៨.៧.៩៩ ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :

១_ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៣.០២.៩៩ របស់មេធាវី ការពារអោយ ឈ្មោះ គឹម ហេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២_ទទួលពាក្យ សុំចូលតតីយជនឈ្មោះ ខាំ ភៀន ចុះថ្ងៃទី ១៩.៤.៩៩ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣_បញ្ចូលឈ្មោះ ខាំ ភៀន ជាតតីយជន ក្នុងរឿងក្ដីនេះ ។

៤_បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៧៨ "ខ" ចុះថ្ងៃទី ២៤.១២.៩៨ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ វៀរលែងតែចំនុចទី២ នៃ សាលក្រមនេះ តំកល់ទុកជាបានការដដែល ។

៥_បង្គាប់អោយឈ្មោះ គង់ សម្បត្តិ និងប្រពន្ធឈ្មោះ ប៊ិន សោភ័ណ្ឌ និង ឈ្មោះ គឹម ហេង សងប្រាក់ចំនួន ៨០.០០០ ដុល្លារអាមេរិក "ប៉ែតសិបពាន់ដុល្លារអាមេរិក" ការប្រាក់ ៥ភាគរយក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ ៨០.០០០ ដុល្លារអាមេរិក គិតចាប់ពីខែកក្កដា ឆ្នាំ ១៩៩៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន ព្រមទាំងជំងឺចិត្ត ចំនួន ២.៥០០ ដុល្លារអាមេរិក "ពីរពាន់ប្រាំរយដុល្លារអាមេរិក" ទៅអោយឈ្មោះ ខាំ ភៀន ។ សំណូមពរលើសពីនេះ បដិសេធចោល ។

ករណីគ្មានប្រាក់សង សំរេចរឹបអូសដី និង ផ្ទះ ដែលមានបណ្ណ័សំគាល់សិទ្ធិកាន់កាប់ អចលនវត្ថុលេខ ភព ០០៧៦២ ចុះថ្ងៃទី ២៩.៥.៩៨ ដើម្បីលក់ឡាយឡុង ធានាសំណង ។ ក្នុងករណីរឹងរូស ត្រូវចាប់ដាក់គុកបង្ខំរូបកាយតាមច្បាប់ ស្ដីពីវិធីអនុវត្តសាលក្រមក្នុងរឿង រដ្ឋប្បវេណី ។

៦_កាត់យកប្រាក់ប្រដាប់ក្ដី ជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០៛ ដែលដើម

បណ្តឹងឧទ្ធរណ៍ បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និង លើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

បង្គាប់អោយឈ្មោះ គង់ សម្បត្តិ , ប៊ិន សោភ័ណ្ឌ និង គឹម ហេង បង់ពន្ធសមាមាត្រ ១ភាគរយ លើចំនួនប្រាក់ដើម ៨០.០០០ ដុល្លាអាមេរិក និង លើចំនួនការប្រាក់ ៥ភាគរយ ក្នុងមួយឆ្នាំ នៅពេលសាលដីកានេះ ចូលជាស្ថាពរ ។ ប្រាក់នេះ ដាក់ចូល ថវិការដ្ឋចំនួន ៨០ ភាគរយ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៧-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ និង តតិយជន កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងតវ៉ា ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៤៤ ចុះថ្ងៃទី ១៦.៧.៩៥ របស់ឈ្មោះ គង់ សម្បត្តិ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាចុះថ្ងៃទី ១២.៨.៩៥ របស់ឈ្មោះ គង់ សម្បត្តិ ។

បានឃើញសារណាតប ចុះថ្ងៃទី ៣០.៨.៩៥ របស់ឈ្មោះ ស្លូង ចាន់ថន ជាមេធាវីការពារអោយឈ្មោះ គឹម ហេង ។

បានឃើញសារណាតប ចុះថ្ងៃទី ១០.៩.៩៥ របស់ឈ្មោះ ខាំ ភៀន ។

បានស្តាប់របាយការណ៍ របស់ ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា :

-បណ្តឹងសាទុក្ខរបស់ដើមចោទ ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។ សាលដីការបស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ហើយ ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ គង់ សម្បត្តិ ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា :

-ខ្លួនត្រូវការលុយ យកទៅលេងគេជាបន្ទាន់ក៏យកប្លង់ផ្ទះទៅបញ្ចាំជាមួយឈ្មោះ គឹម ហេង ព្រោះឈ្មោះនេះថាមានលុយ ដើម្បីយកប្រាក់ ៨០.០០០ដុល្លារអាមេរិក តែខ្លួនទទួលបានតែ ១០.០០០ ដុល្លាអាមេរិកប៉ុណ្ណោះ ហើយឈ្មោះនេះ ចេះតែគេចរហូត នៅពេលខ្លួនទាមទារលុយដែលនៅខ្វះទៀត ក្រោយមកឈ្មោះនេះ ក៏ជាប់គុកបាត់ទៅ ។ ខ្លួនមិនដែលស្គាល់ឈ្មោះ ខាំ ភៀន ទេ ហើយទំនាក់ទំនង រវាងឈ្មោះ គឹម ហេង និង ឈ្មោះ ខាំ ភៀន យ៉ាងណានោះ ក៏ខ្លួន មិនដឹងដែរ ។ ដល់ពេលខ្លួនសួរយកប្លង់វិញឈ្មោះ

គឹម ហេង មិនព្រមអោយទេ ដោយប្រាប់ថា យកទៅបញ្ចាំគេហើយ គាត់ក៏មិនជូនប្រាប់ខ្លួនថា យកទៅបញ្ចាំជាមួយអ្នកណាដែរ ។

ក្រឡាបញ្ជី អានសារណា របស់ ឈ្មោះ

-គឹម ហេង

-ខាំ ភៀន

មេធាវីរបស់ដើមចោទធ្វើសេចក្តីសន្និដ្ឋានថា :

-កូនក្តីខ្លួនយកប្លង់ផ្ទះទៅបញ្ចាំ ជាមួយឈ្មោះ គឹម ហេង ដោយឈ្មោះនេះថា មានលុយ ដោយធ្វើលិខិតស្នាមត្រឹមត្រូវ ដើម្បីយកលុយ នៅពេលនោះកូនក្តីខ្លួនបានលុយតែ១០.០០០ ដុល្លាអាមេរិក បើឈ្មោះ គឹម ហេង ចេះតែគេចវេះ នៅពេលកូនក្តីខ្លួន ទាមទារលុយដែលខ្វះ ព្រោះប្លង់នោះយកទៅបញ្ចាំដើម្បីយកលុយចំនួន ៨០.០០០ ដុល្លារអាមេរិក ពេលនោះកូនក្តីខ្លួនក៏ទាមទារយកប្លង់វិញ តែឈ្មោះនេះប្រាប់ថា យកទៅបញ្ចាំគេបាត់ ហើយក៏មិនព្រមប្រាប់អាស័យដ្ឋាន ដែលយកទៅបញ្ចាំនោះដែរ ។ ពេលនោះកូនក្តីខ្លួនក៏ប្តឹងទៅ តុលាការ ដើម្បីសុំកិច្ចការប្រញាប់ បដិសេធបណ្ណ័សំគាល់អចលនវត្ថុនោះចោល ។ ឯការខ្ចីលុយរវាងឈ្មោះ គឹម ហេង និង កូនលោកជំទាវ ខាំ ភៀន មានតែពីរនាក់គត់ ។

សំណូមពរ

-បដិសេធសាលដីការបស់សាលាឧទ្ធរណ៍

-ទាមទារលុយ ៧០.០០០ ដុល្លារទៀត និង ការប្រាក់ពីឈ្មោះ គឹម ហេង

-ទាមទារយកប្លង់វិញ បើមិនព្រមប្រគល់អោយវិញទេ សុំចេញបណ្ណ័កម្មសិទ្ធិថ្មីអោយកូនក្តីខ្លួន ។

មេធាវី របស់តតិយជនធ្វើសេចក្តីសន្និដ្ឋានថា :

-សុំតំកល់ សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល

-បដិសេធសារណា របស់គូភាគី

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ ចម្លើយរបស់លោក គង់ សម្បត្តិ សារណារបស់អ្នកស្រី គឹមហេង និង អ្នកស្រី ខាំ ភៀន និង សេចក្តីសន្និដ្ឋាន របស់មេធាវី នៃ គូភាគី

-ក្រោយពីបាន ពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៤៤ ចុះថ្ងៃទី ១៦.៣.៩៩ របស់លោក គង់សម្បត្តិ

ស្ថិតក្នុងកំរិតច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤នៃច្បាប់ស្តីពីការ ចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលដើមចោទលើកឡើងក្នុងសារណា របស់ខ្លួនថា សាលាឧទ្ធរណ៍ សំរេចអោយខ្លួន ប្រពន្ធ និង ចុងចម្លើយ សងទៅអ្នកស្រី ខាំ ភៀន ជាតពីយជន តាមអំណាចសាលដីកាលេខ ៤១៥ ចុះថ្ងៃទី ០៨.៧.៩៩ ថាជាការពុំត្រឹមត្រូវនោះ ជាការភន្តច្រឡំ ពីព្រោះថា ការដែលតពីយជនអ្នកស្រី ខាំ ភៀន ព្រមប្រគល់ប្រាក់ឱ្យចុងចម្លើយខ្ចីនោះ គឺអាស្រ័យដោយដើមចោទ ប្រគល់ប័ណ្ណកម្មសិទ្ធិផ្ទះ អោយចុងចម្លើយ ដើម្បីដាក់បញ្ចាំ ជាវត្ថុធានា ដោយបានទាំងធ្វើលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ០៨.៦.៩៨ ជូនចុងចម្លើយផងដែរ ដូច្នេះទាំងដើមចោទ ទាំងចុងចម្លើយ ត្រូវជាប់កាតព្វកិច្ចដូចគ្នា ក្នុងការសងបំណុលតាមមាត្រា ៧០ និង មាត្រា ១១២ នៃ ក្រឹត្យ-ច្បាប់ លេខ ៣៨ក្រច ចុះថ្ងៃទី ២៨.១០.៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

-យល់ឃើញថា អ្នកស្រី គីម ហេង និង អ្នកស្រី ខា ភៀន បានផ្ញើសារណាការពារជូនមក តុលាការកំពូល រួចហើយ ប៉ុន្តែអ្នកស្រីពុំបានមកចូលរួមនាសវនាការនេះទេ តុលាការកំពូល ជំនុំជំរះរឿងនេះ កំបាំងមុខអ្នកស្រី ប៉ុន្តែ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៤១៥ ចុះថ្ងៃទី ០៨.៧.៩៩ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខលោក គង់ សម្បត្តិ កំបាំងមុខ អ្នកស្រី គីម ហេង និង អ្នកស្រី ខាំ ភៀន ប៉ុន្តែចាត់ទុកជាចំពោះមុខ .

១-ទទួលបណ្តឹងសាទុក្ខលេខ ២៤៤ ចុះថ្ងៃទី ១៦.៧.៩៩ របស់លោក គង់ សម្បត្តិ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៤១៥ ចុះថ្ងៃទី ០៨.៧.៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ដែលដើមចោទ បានបង់ទុកនៅ តុលាការកំពូល ចំនួន ១៨.០០០ ៛ គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ .



៣៧

-ចំណាយក្នុងការ ប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។
បង្គាប់អោយដើមចោទ បង់ពន្ធសមាមាត្រ តាមការកំណត់ របស់សាលាឧទ្ធរណ៍ ។
នៃសាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ២១ ខែ
ធ្នូ ឆ្នាំ ១៩៩៩ ។